អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៣/២៣ ចេញផ្សាយ ខែមករា ឆ្នាំ២០២៣

## អ្វីទៅជាសវនកម្មសមិទ្ធកម្ម

ទិដ្ឋភាពទូទៅនៃសវនកម្មសមិទ្ធកម្ម÷ ជាទូទៅនៅគ្រប់បណ្តាស្ថាប័ន/អង្គភាព ទាំងអស់អាចរីកចម្រើនទៅបាន អាស្រ័យលើភាពល្អប្រសើរនៃប្រតិបត្តិការរបស់ខ្លួន។ តាមរយៈនេះ ការធ្វើសវនកម្មសមិទ្ធកម្មជាភាពចាំបាច់មួយក្នុងការរួមចំណែក តាមដានត្រួតពិនិត្យ និងកែតម្រូវលើភាពអសកម្មនៃប្រតិបត្តិការរបស់ស្ថាប័ន/អង្គភាព នោះឱ្យមានភាពល្អប្រសើ។




តាមរយៈការសិក្សាទៅលើគោលការណ៍ណែនាំ និងស្តង់ដាសវនកម្មសមិទ្ធកម្ម របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និយមន័យសវនកម្មសមិទ្ធកម្មត្រូវបានកំណត់ដូចខាងក្រោម÷

សវនកម្មសមិទ្ធកម្ម សំដៅដល់ការត្រួតពិនិត្យដោយឯករាជ្យលើប្រសិទ្ធភាព និងប្រសិទ្ធផលការងារ កម្មវិធី ឬស្ថាប័ន/អង្គភាព ទាក់ទងនឹងភាពសន្សំសំចៃ និងឈានទៅរកភាពប្រសើរឡើង។

ជាមួយគ្នានេះដែរ ចំពោះការសិក្សាស្រាវជ្រាវទៅលើអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល INTOSIA (ISSAI 300-Performance Audit Principles) និយមន័យសវនកម្មសមិទ្ធកម្មត្រូវបានកំណត់ដូចខាងក្រោម÷

សវនកម្មសមិទ្ធកម្ម ជាការពិនិត្យដោយឯករាជ្យ គោលបំណង និងការជឿទុកចិត្តបាន ថាតើការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ប្រព័ន្ធ ប្រតិបត្តិការ កម្មវិធី សកម្មភាព ឬស្ថាប័ន/អង្គភាព កំពុងដំណើរការស្របតាមគោលការណ៍ សេដ្ឋកិច្ច ប្រសិទ្ធភាព និងប្រសិទ្ធផល ដែរឬទេ។

សវនកម្មសមិទ្ធកម្ម មិនមែនជាកម្មវត្ថុនៃតម្រូវការ និងការរំពឹងទុកជាក់លាក់ពេកនោះទេ ដោយអាចមានភាពបត់បែនច្រើនក្នុងការជ្រើសរើសប្រធានបទ គោលដៅ វិធីសាស្ត្រ និងមតិយោបល់សវនកម្ម។ សវនកម្មនេះ អាចមានគោលបំណងដើម្បីពិនិត្យមើលលើទិដ្ឋភាពមួយ ឬច្រើនក្នុងចំណោមទិដ្ឋភាពទាំងបី (ប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ)។ ការធ្វើសវនកម្មសមិទ្ធកម្មគឺដើម្បីស្វែងរកនិងផ្តល់ឱ្យនូវព័ត៌មានថ្មីៗ ការវិភាគ ឬការយល់ដឹងចំណុចល្អប្រសើរ និងអនុសាសន៍ដើម្បីកែលម្អជាដើម។ សវនកម្មសមិទ្ធកម្ម ផ្តល់នូវព័ត៌មានថ្មី ចំណេះដឹង និងគុណតម្លៃតាមរយៈ÷

-ផ្តល់ឱ្យនូវចំណេះដឹងពីការវិភាគថ្មី (ការវិភាគយ៉ាងទូលាយ ឬស៊ីជម្រៅ ឬក៏ទស្សនៈវិស័យថ្មីៗ)

-ផ្តល់ភាពងាយស្រួលទៅកាន់ ស្ថាប័ន/អង្គភាព ដែលពាក់ព័ន្ធក្នុងការប្រើប្រាស់ព័ត៌មានដែលមានស្រាប់

-ផ្តល់ឱ្យនូវ ឯករាជ្យភាព និងទស្សនៈបែបផ្លូវការ ឬការសន្និដ្ឋានដោយផ្អែកលើភស្តុតាងសវនកម្ម

-ផ្តល់ឱ្យនូវអនុសាសន៍ដើម្បីកែលម្អដោយផ្អែកលើការវិភាគទៅលើលទ្ធផលរកឃើញ

សវនកម្មសមិទ្ធកម្ម អាចរកឃើញវិធានការដែលប្រើមិនមានប្រសិទ្ធភាព និងមិនស្របតាមគោលបំណង ប៉ុន្តែ ស្របពេលដែលសវនករចាប់ផ្តើមសួរសំណួរទៅសវនដ្ឋាន សវនករត្រូវប្រយ័ត្នមិនត្រូវចេញហួសដែនសមត្ថកិច្ចរបស់ខ្លួន ឆ្លងខ្សែបន្ទាត់ចូលបញ្ហានយោបាយឡើយ។

**អត្ថបទ÷** លោក **មឿន គីមសាន**

**ឯកសារយោង÷**

១- *គោលការណ៍ណែនាំ និងស្តង់ដាសវនកម្មសមិទ្ធកម្មរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

២-INTOSAI *(ISSAI 300-Performance Audit Principles)*។